# វិកគី តាឌីក

*អ្នកប្រែចិត្តជឿជំនាន់ដំបូង នៅក្នុងប្រទេសបូស្នី និង ហឺរ៍ស្សេហ្គូវីណា*

**ដោយ លូស៊ី ស្ទីវ៉ែនសុន អ៊ីវែល**
ទស្សនាវដ្ដីសាសនាចក្រ( ផ្អែកទៅលើដំណើររឿងពិត )

73

ប្រទេសបូស្នី និង ហឺរ៍ស្សេហ្គូវីណា មានសមាជិកសាសនាចក្រចំនួន ៧៣ នាក់ ។



ព្រះវិហារបរិសុទ្ធដែលជិតប្រទេសបូស្នី និង ហឺរ៍ស្សេហ្គូវីណា បំផុត គឺ ព្រះវិហារបរិសុទ្ធ រ៉ូមអ៊ីតាលី ។



ប្រទេសបូស្នី និង ហឺរ៍ស្សេហ្គូវីណា មានទីតាំងនៅក្នុងទ្វីបអឺរ៉ុបភាគអាគ្នេយ៍ ។

« មកលឿនឡើង ! » ប្អូនប្រុសរបស់វិកគីបានហៅ ។ « តោះ ទៅលេងជាមួយគ្រួសាររ៉ូវ ! » គ្រួសាររ៉ូវជាអ្នកជិតខាងថ្មីរបស់ពួកគេ ។ ពួកគេបានប្ដូរលំនៅពីសហរដ្ឋ មកប្រទេសបូស្នី និង ហឺរ៍ស្សេហ្គូវីណា ។ ពួកគាត់មានកូនៗអាយុតំណាលវិកគី និងបងប្អូននាងដែរ ។ ប៉ុន្តែពួកគេមិននិយាយភាសាបូស្នីទេ ។ វិកគីជាមនុស្សតែម្នាក់ប៉ុណ្ណោះ ដែលនិយាយភាសាអង់គ្លេស ។ នាងបានបកប្រែដើម្បីពួកគេអាចលេងជាមួយគ្នាបាន ។

វិកគីបានអង្គុយជាមួយអ្នកស្រីរ៉ូវនៅរានហាល ខណៈក្មេងៗដទៃទៀតលេង ។

វិកគីបាននិយាយថា « គ្រួសាររបស់អ្នកស្រីហាក់ដូចជាខុសពីគេណាស់ » ។ « និយាយតាមផ្លូវល្អ » ។

អ្នកស្រីរ៉ូវបានញញឹម ។ « តើក្មួយចង់ទៅព្រះវិហារជាមួយពួកយើងទេ ? នោះប្រហែលជាជួយក្មួយឲ្យឃើញថា ហេតុអ្វីយើងខុសពីគេ ។ ព្រះវិហាររបស់យើងមិនមានអគារនៅបូស្នីនេះទេ ដូច្នេះយើងមានព្រះវិហារជាមួយគ្រួសារយើងនៅផ្ទះ » ។

វិកគីចង់ដឹងណាស់ ពេលនាងបានមកដល់ផ្ទះគ្រួសាររ៉ូវនៅថ្ងៃអាទិត្យ ។ ដំបូងឡើយ ពួកគេច្រៀងចម្រៀងមួយបទ ។ កូនរបស់ពួកគាត់ម្នាក់បានអធិស្ឋាន ។ បន្ទាប់មក លោករ៉ូវបានអធិស្ឋាន ហើយចែកនំប៉័ង និងទឹកដល់ពួកគេម្នាក់ៗ ។ ពួកគាត់បានប្រាប់ថា គេហៅវាថាសាក្រាម៉ង់ ។ បន្ទាប់មកកូនស្រីរបស់គាត់ឈ្មោះ ជេសស៊ី បានថ្លែងសក្ខីភាព ។

ជេសស៊ីបាននិយាយថា « ព្រះវរបិតាសួគ៌ស្រឡាញ់យើង ។ ទ្រង់មានបន្ទូលមកកាន់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ » ។ « ជួនកាល ព្រះវិញ្ញាណបរិសុទ្ធប្រទានដល់យើងនូវអារម្មណ៍ដ៏សុខសាន្ត ។ ឬជួនកាល ទ្រង់ប្រទានដល់យើងជាគំនិតមួយ » ។

ថ្ងៃបន្ទាប់ទៀត វិកគីបានដើរទៅហាងទំនិញដើម្បីទិញនំប៉័ង ។ នៅតាមផ្លូវត្រឡប់មកផ្ទះវិញ នាងរៀបនឹងដើរកាត់ធុងសម្រាម ពេលមានសំឡេងមួយក្នុងគំនិតនាងបានបញ្ឈប់នាង ។សំឡេងនោះបាននិយាយថា *នៅឲ្យឆ្ងាយ* ។

វិកគីបានឈរស្ងៀមទ្រឹង ។ ភ្លាមនោះ មានឡានមួយបានបើកមករេចង្កូតវិលជុំវិញជ្រុងនោះ ។ *បុកប្រាវ!* ឡានបានបុកធុងសម្រាម ។

វិកគីបានដកដង្ហើមធំ ។ នាងសប្បាយចិត្តខ្លាំងណាស់ដែលនាងស្ដាប់តាមសំឡេងនោះ !

ក្រោយមក វិកគីបានប្រាប់ដំណើររឿងនោះទៅអ្នកស្រីរ៉ូវ ។ « តើនោះជាព្រះវិញ្ញាណបរិសុទ្ធឬ ? »

« ស្ដាប់ទៅដូចជាអញ្ចឹងហើយ ។ ជួនកាល ព្រះវិញ្ញាណបរិសុទ្ធព្រមានយើងអំពីគ្រោះថ្នាក់ » ។

វិកគីបាននិយាយថា « ព្រះបានការពារខ្ញុំ » ។ « ខ្ញុំនឹងស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធជានិច្ច » ។

វិកគីបានបន្តទៅផ្ទះគ្រួសាររ៉ូវ ដើម្បីចូលរួមព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ ។ បន្ទាប់មក វិកគីបានចែកចាយព្រះគម្ពីរមរមនជាមួយនឹងម្ដាយនាង ។ មិនយូរប៉ុន្មាន គ្រួសារនាងទាំងមូលបានរៀនអំពីដំណឹងល្អពីគ្រួសាររ៉ូវ ។ វិកគីបានបកប្រែសម្រាប់អ្នកគ្រប់គ្នា ។



វិកគីចូលចិត្តសកម្មភាពនៅខាងក្រៅ ។ ការឡើងភ្នំជាអ្វីមួយដែលនាងចូលចិត្តធ្វើ ។

16

វិកគីបានទទួលពិធីបុណ្យជ្រមុជទឹកនៅអាយុ ១៦ ឆ្នាំ ។



ពេលវិកគីបានធំឡើង នាងបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ។ ឥឡូវនេះ នាងមានកូនពីរនាក់ ។




ថ្ងៃមួយលោករ៉ូវបានសួរសំណួរមួយទៅគ្រួសារវិកគី ។ វិកគីបានថាតាមសំណួរនោះជាភាសាបូស្នី ។ « តើបងប្អូននឹងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលបុណ្យជ្រមុជទឹកដែរឬទេ ? »

វិកគីបានរង់ចាំ ។ នាងចង់ទទួលបុណ្យជ្រមុជទឹក ។ ប៉ុន្តែនាងភ័យ អំពីអ្វីដែលគ្រួសារនាងនឹងនិយាយ ។

នៅទីបំផុត ប៉ារបស់វិកគីបាននិយាយ ។ *«ដា»* ។

*«ដា»* គ្រួសារនាងបាននិយាយជាភាសា បូស្នី ។

វិកគីសប្បាយចិត្តខ្លាំងណាស់ នាងមានអារម្មណ៍ថាបេះដូងនាងនឹងផ្ទុះ ។ នាងបាននិយាយទៅលោករ៉ូវថា « ចាស» ។ « ចាស ពួកខ្ញុំយល់ព្រម » ។

មួយសប្ដាហ៍ក្រោយមក វិកគី និងគ្រួសារនាងបានបើកឡានប្រាំម៉ោងទៅកាន់អគារសាសនាចក្រដែលជិតបំផុត ។ វិកគីមានអារម្មណ៍សប្បាយចិត្តកាលដែលនាងបានឈានជើងចូលក្នុងទឹកដើម្បីទទួលបុណ្យជ្រមុជទឹក ។ នាងកាន់តែមានអារម្មណ៍សប្បាយខ្លាំងឡើង ពេលនាងបានទទួលការបញ្ជាក់ជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ឥឡូវនេះ នាងនឹងមានព្រះវិញ្ញាណបរិសុទ្ធនៅជាមួយនាង *ជានិច្ច ។*●